ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១០៤៤៥ ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីសៀវភៅស្នាក់នៅ
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីសៀវភៅគ្រួសារ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់នីតិវិធី និងបែបបទសម្រាប់អាជ្ញាធរឃុំ សង្កាត់ ចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋដែលមានលំនៅឋាន ឬទីសំណាក់ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលបានចុះក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ហើយមិនទាន់មានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ សម្រាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត។

**ប្រការ២.-**

លំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណា[illegible]

ទុកជាជាល់នៅឋាន។ ទីសំណាក់សំដៅលើទីស្ថានដែលបុគ្គល ម្នាក់ស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែងក្នុងរយៈពេលជាកំណត់ណាមួយ។

**ប្រការ៣._**

មេឃុំ ចៅសង្កាត់ ជាតំណាងឲ្យអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅតាមប្រការទាំងឡាយនៃប្រកាសនេះ។

ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន ត្រូវប្រគល់សិទ្ធិជាលាយល័ក្ខអក្សរជូនជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមឲ្យបំពេញការងារនេះជំនួស។

**ប្រការ៤._**

ដើម្បីធានាសិទ្ធិបោះឆ្នោត ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬទីសំណាក់ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលបានចុះក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ហើយមិនទាន់មានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ អាចស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនមានលំនៅឋាន ឬទីសំណាក់ ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត។ អាជ្ញាធរឃុំ សង្កាត់ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅនេះជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលានៃការចុះឈ្មោះបោះឆ្នោត។

**ប្រការ៥._**

ដើម្បីទទួលបានលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំ សង្កាត់ ប្រជាពលរដ្ឋខ្មែរដូចចែងក្នុងប្រការ៤ ត្រូវទៅបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ ដែលសាមីខ្លួនមានលំនៅឋាន ឬទីសំណាក់ ដែលត្រូវចុះឈ្មោះបោះឆ្នោត។

**ប្រការ៦._**

ក្នុងពេលទៅបង្ហាញខ្លួន ប្រជាពលរដ្ឋខ្មែរត្រូវនាំទៅជាមួយនូវ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន និង
- សាក្សី១ (មួយ)រូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយ។

**ប្រការ៧._**

សាក្សី ដូចចែងក្នុងប្រការ៦ នៃប្រកាសនេះ ត្រូវនាំយកទៅជាមួយនូវ ឯកសារផ្លូវការដែលមានចុះអំពីលំនៅឋាន ឬទីសំណាក់របស់សាក្សីនោះ។

**ប្រការ៨._**

ករណីពិនិត្យឃើញប្រជាពលរដ្ឋបានបំពេញតាមនីតិវិធី និងបែបបទស្របតាមប្រកាសនេះហើយ មេឃុំ ចៅសង្កាត់ ឬអ្នកដែលបានទទួលការផ្ទេរសិទ្ធិ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋនោះដោយមិនត្រូវពន្យាពេលវេលាឡើយ ។

លិខិតបញ្ជាក់ទីលំនៅនេះផលិតដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។ ~~

**ប្រការ៩.-**

ការចេញលិខិតបញ្ជាក់ទីលំនៅសម្រាប់គោលដៅ នៃការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងប្រកាសនេះ មិនតម្រូវឲ្យប្រជាពលរដ្ឋបង់ថ្លៃសេវារដ្ឋបាលឡើយ។

**ប្រការ១០.-**

ប្រជាពលរដ្ឋខ្មែរ ដូចចែងក្នុងប្រការ៤ នៃប្រកាសនេះ មានសិទ្ធិសុំលិខិតបញ្ជាក់ទីលំនៅបានតែនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោតប៉ុណ្ណោះ។

**ប្រការ១១.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រការទាំងឡាយនៃប្រកាសនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់។

**ប្រការ១២.-**

ប្រកាសលេខ២៨២៨ ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត អភិបាលក្រុងស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ [illegible] ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ១៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...........................................
ក្រុង ស្រុក ខណ្ឌ.........................................
ឃុំ សង្កាត់................................................

លេខ: 000000000 .....

# លិខិតបញ្ជាក់ទីលំនៅ

យោងប្រកាសលេខ..... ប្រ.ក ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០១... របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត។

យើងមេឃុំ ចៅសង្កាត់.......................................................សូមបញ្ជាក់ថា៖

- ឈ្មោះ.......................................................................ភេទប្រុស □ ស្រី □
- កើតនៅថ្ងៃ............ទីខែ.................ឆ្នាំ.................. ពិតជាមានលំនៅឋានឬទីសំណាក់
- លេខ.................ផ្លូវ....................ភូមិ.................ឃុំ សង្កាត់.................

ក្រុង ស្រុក ខណ្ឌ.......................រាជធានី ខេត្ត.......................ពិតប្រាកដមែន។

លិខិតបញ្ជាក់ទីលំនៅនេះធ្វើឡើងដោយផ្អែកលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានលេខ...................................................និងការឆ្លើយបញ្ជាក់របស់សាមីខ្លួន និងសាក្សី៖

- ឈ្មោះ.......................................................................ភេទប្រុស □ ស្រី □
- កើតនៅថ្ងៃទី............ខែ.................ឆ្នាំ..................មានលំនៅឋានឬទីសំណាក់

លេខ.................ផ្លូវ....................ភូមិ.................ឃុំ សង្កាត់.................

ក្រុង ស្រុក ខណ្ឌ.......................................រាជធានី ខេត្ត.......................

ពិតជាត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

លិខិតបញ្ជាក់ទីលំនៅនេះ ចេញជូនសាមីខ្លួន សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត។

ធ្វើនៅថ្ងៃទី..........ខែ..............ឆ្នាំ..........

ស្នាមមេដៃ

មេឃុំ ចៅសង្កាត់

សាមីខ្លួន

សាក្សី